# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អតក

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: **ខ្មែរ**

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១៤

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 08-Oct-2014, 08:48
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយសាលាដំបូង សាធារណៈ/Public

ប្រភេទនៃចំណាត់

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សំណើសុំឲ្យបញ្ចប់ដល់ផ្នែករដ្ឋបាលពង្រឹងសមត្ថភាពរបស់អង្គភាពបកប្រែភាសាជាបន្ទាន់

---

ដាក់ដោយ៖

**សហមេធាវីការពារក្ដីលោក ខៀវ សំផន**

លោក គង់ សំអុន

លោកស្រី Anta GUISSÉ

លោក Arthur VERCKEN

**អ្នកជំនួយការ**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Soumeya MEDJEBEUR

លោក Pierre TOUCHE

កញ្ញា អ៊ុច ស្រីផាត

ផ្ញើជូន៖

**អង្គជំនុំជម្រះតុលាការកំពូល**

ចៅក្រម គង់ ស្រីម

ចៅក្រម Agnieszka KLONOWIECKA-MILART

ចៅក្រម សោម សិរីវុឌ្ឍ

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម យ៉ា ណារិន

ចៅក្រម Florence Ndepele MUMBA

**សហព្រះរាជអាជ្ញា៖**

កញ្ញា Cécile ROUBEIX

លោក BOSSIS Clément

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**មេធាវីនៃដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីខាងការពារក្ដីរបស់លោក នួន ជា**

# សូមគោរពអង្គជំនុំជម្រះតុលាការកំពូល

១. នៅក្នុងដំណាក់កាលបច្ចុប្បន្ននៃនីតិវិធី ក្នុងសំណុំរឿង ០០២ វាជាការសំខាន់ណាស់ដែលត្រូវពង្រឹងសមត្ថភាពនៃអង្គភាពបកប្រែភាសា ("អង្គភាពបកប្រែ") ជាបន្ទាន់ ដើម្បីបំពេញតម្រូវការអង្គជំនុំជម្រះ និងភាគី ក្នុងផ្នែកបកប្រែ។ បើពុំនោះទេ ការយឺតយ៉ាវដែលបង្កឡើងដោយបញ្ហាលំបាកនៃអង្គភាពនេះក្នុងការបកប្រែឯកសារមិនទាន់ពេលវេលាចាំបាច់ លុះយូរៗទៅអាចនឹងកាន់តែធ្ងន់ធ្ងរឡើង ហើយនឹងរាំងស្ទះដល់ *"ភារកិច្ចរបស់ អ.វ.ត.ក ក្នុងការសម្រេច* [លើបទចោទប្រឆាំងនឹង លោក នួន ជា និង លោក ខៀវ សំផន] *តាមពេលវេលាសមស្របបាននោះទេ"* [1]។ អង្គជំនុំជម្រះតុលាការកំពូល ("តុលាការកំពូល") ក៏បានសម្រេចយ៉ាងដូច្នោះដែរ *"ដូចនេះ ជាការតម្រូវថា អ.វ.ត.ក ដំណើរការជារៀងរាល់ថ្ងៃ រាល់ថ្ងៃដែលខ្លួនអាចធ្វើទៅបាន ដើម្បីធានាបាននូវការសម្រេចជាស្ថាពរលើបទចោទដែលសេសសល់ ឱ្យបានឆាប់ដែលអាចធ្វើទៅបាន"*។[2]

២. ថ្ងៃនេះ ក្រុមមេធាវីការពារក្តី លោក ខៀវ សំផន ("ក្រុមមេធាវីការពារក្តី") ស្នើសុំអន្តរាគមន៍ពីតុលាការកំពូល ដើម្បីបង្គាប់ដល់ផ្នែករដ្ឋបាលតុលាការឱ្យពង្រឹងជាបន្ទាន់នូវសមត្ថភាពរបស់អង្គភាពបកប្រែ សម្រាប់ការបកប្រែឯកសារនេះ។ ម៉្យាងវិញទៀត ក្រុមមេធាវីការពារក្តីក៏បានធ្វើសំណើដូចគ្នានេះ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ("សាលាដំបូង") ផងដែរ។

## I. សារសំខាន់នៃភាសានីមួយៗក្នុងភាសាការងារទាំងបីនៃ អ.វ.ត.ក

៣. ដោយយោងទៅអត្ថបទច្បាប់នៃ អ.វ.ត.ក តុលាការកំពូលមានឱកាសក្នុងការរំឭកថា ៖

> *"ភាសាប្រើប្រាស់ជាផ្លូវការរបស់ អ.វ.ត.ក គឺភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង។ អាស្រ័យហេតុនេះ ឯកសារទាំងអស់ នៅអ.វ.ត.ក ត្រូវតែដាក់ជាភាសាខ្មែរ និងភាសាអង់គ្លេស ឬ ភាសាបារាំង ហើយភាគីអាចស្នើសុំបកប្រែជាភាសាផ្សេងទៀតបាន។"*[3]

---

[1] ឧទាហរណ៍ សូមមើល សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ **E163/5/1/13** កថាខណ្ឌទី៥១។

[2] ដូចខាងលើ។

[3] សេចក្តីសម្រេចលើសំណើរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន សុំឱ្យអង្គជំនុំជម្រះតុលាការកំពូលជូនដំណឹងជាបី

៤. តុលាការកំពូល ក៏បានរំឭកផងដែរថា ការដាក់ឯកសារជាច្រើនភាសា *"គឺដើម្បីឲ្យស្ថាប័នជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធនៃ អ.វ.ត.ក អាចពិនិត្យមើលលើឯកសារទាំងអស់នេះបាន ត្រឹមត្រូវ"*។[4]

៥. ម្យ៉ាងទៀត តុលាការកំពូល បានប្រកាសទៀតថាខ្លួន *"ទទួលស្គាល់ការចង់បានជាទូទៅនៃការដាក់ឯកសារជាបីភាសាក្នុងពេលដំណាលគ្នា"*។[5]

៦. វាមិនមែនជាការឥតប្រយោជន៍នោះឡើយក្នុងការគូសបញ្ជាក់ថា តាមពិត គ្មានអត្ថបទច្បាប់ណាមួយនៃ អ.វ.ត.ក ដែលកំណត់កាតព្វកិច្ច ដែលទាមទារឲ្យភាគី ឬចៅក្រមត្រូវចេះភាសាបី ឬចេះភាសាពីរនោះឡើយ។[6]

៧. ខណៈដែលភាគីដទៃទៀត នៅក្នុងសំណុំរឿង 00២ បំពេញការងារជាភាសាអង់គ្លេស និងភាសាខ្មែរ ក្រុមមេធាវីការពារក្តី លោក ខៀវ សំផន បំពេញការងារជាភាសាបារាំង និងភាសាខ្មែរ។ សាលាដំបូងមានសមាសភាពចៅក្រមដែលចេះភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង រីឯតុលាការកំពូល មានសមាសភាពចៅក្រមដែលចេះភាសាខ្មែរ និង ភាសាអង់គ្លេស។

៨. សមាជិកនៃភាគី និងអង្គជំនុំជម្រះទាំងអស់ សុទ្ធតែជាអ្នកច្បាប់ មិនមែនជាភាសាវិទូឡើយ។

---

ភាសាផ្លូវការ ថ្ងៃទី ៣0 ខែ មេសា ឆ្នាំ ២០១៣ **E163/5/1/15** ("សេចក្តីសម្រេច **E163/5/1/15**") កថាខណ្ឌទី ៨ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ តុលាការកំពូលបានយោងទៅមាត្រា ៤៥ នៃច្បាប់ថ្មីនៃការបង្កើត អ.វ.ត.ក និងមាត្រា ៧.១ នៃសេចក្តីណែនាំអនុវត្តសម្រាប់ការដាក់ឯកសារចំពោះមុខ អ.វ.ត.ក ("សេចក្តីណែនាំអនុវត្ត")។ សូមអានផងដែរ មាត្រា ៧.៣ នៃសេចក្តីណែនាំដដែលនោះ ដែលបញ្ជាក់ថា *"ផ្នែកគ្រប់គ្រងតុលាការ ត្រូវធានាថា ការបកប្រែឯកសារ អាចធ្វើទៅបាន តាមពេលវេលាដូចមានកំណត់នៅក្នុងសេចក្តីណែនាំអនុវត្តនេះ។"*

[4] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹង សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើសំណើសុំដោះលែង ខៀវ សំផន ឲ្យនៅក្រៅឃុំជាបន្ទាន់ ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៣ **E275/2/3** កថាខណ្ឌទី ១៣ ។

[5] សេចក្តីសម្រេច E163/5/1/15 កថាខណ្ឌទី ៨។

[6] សូមអានចំណុចពាក់ព័ន្ធនឹងក្រុមការងារនៃអង្គភាពគាំពារការការពារក្តី : http://www.cccc.gov.kh/fr/dss/la-liste-des-avocats។

## II. អសមត្ថភាពរបស់អង្គភាពបកប្រែក្នុងការឆ្លើយតបទៅនឹងតម្រូវការបច្ចុប្បន្ន និងនៅថ្ងៃអនាគត

### ១. តម្រូវការផ្នែកបកប្រែសំណេរពីភាសាអង់គ្លេសមកជាភាសាបារាំង

៩. ដោយសារតែជាក្រុមការងារតែមួយគត់ដែលត្រូវបំពេញការងារជាភាសាបារាំង បន្ថែមពីលើភាសាខ្មែរ សឹងតែរាល់លើកទៅហើយ ក្រុមមេធាវីការពារក្តីស្នើសុំឱ្យមានការបកប្រែជាភាសាបារាំង នូវសំណេររបស់ភាគីដទៃទៀត និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះដែលមិនមានដាក់ឬស្នើសុំឱ្យបកប្រែជាភាសាបារាំង។

១០. នៅក្នុងរយៈពេលតាក់តែងសាលក្រមក្នុងសំណុំរឿង ០០២/០១ អស់រយៈពេលជាច្រើនខែ ដែលអង្គភាពបកប្រែបានខិតខំបំពេញការងារបកប្រែនេះដោយទុកជាអាទិភាព សំណើសុំបកប្រែឯកសារជាច្រើនដែលស្នើឡើងដោយក្រុមមេធាវីការពារក្តី មិនត្រូវបានបំពេញតាមបំណងឡើយ។ តែយើងមិនអាចធ្វើអ្វីក្រៅពីសង្កេតឃើញថា ស្ថានភាពនោះមិនមានការកែលម្អឡើយ តាំងពីថ្ងៃចេញសាលក្រម ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ នោះមក។ ការយឺតយ៉ាវជាបន្តបន្ទាប់ចំពោះការស្នើសុំដែលធ្វើបានធ្វើឡើងមុនកាលបរិច្ឆេទនោះ មិនត្រូវបានបំពេញសោះឡើយ។ លើសពីនោះ ការស្នើសុំក្រោយៗមកទៀត ក៏មិនត្រូវបានបំពេញតាមបំណងដែរ។

១១. ជាឧទាហរណ៍ ក្រុមមេធាវីការពារក្តីនៅកំពុងរង់ចាំ ឯកសារបកប្រែជាភាសាបារាំងចំនួន ២៩ ច្បាប់ [7] ដែលបានស្នើសុំមុនថ្ងៃទី៧ ខែ សីហា ឆ្នាំ ២០១៤ និង ៩ ច្បាប់ទៀត បន្ទាប់ពីថ្ងៃដដែលនោះ។ ជាឧទាហរណ៍ ការបកប្រែជាភាសាបារាំងនូវសេចក្តីសម្រេចធ្វើឡើងដោយតុលាការកំពូល នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤[8] ដែលត្រូវបានស្នើសុំដំណាលគ្នា ដោយតុលាការកំពូល និងក្រុមមេធាវីការពារក្តី នៅមិនទាន់ទទួលបាននៅឡើយ រហូតមកដល់ថ្ងៃនេះក្នុងខែតុលានេះ។ ឯក្រុមមេធាវីការពារក្តីក៏បានបញ្ជាក់ប្រាប់អង្គភាពបកប្រែជាច្រើនលើកច្រើនសារហើយថា ឯកសារដែលត្រូវបកប្រែមួយនេះ ជាឯកសារអាទិភាពរបស់ខ្លួន។

---

[7] ក្រុមមេធាវីការពារក្តីគិតស្មានថាឯកសារ ៥ ក្នុងចំណោមឯកសារ ២៩ ត្រូវបានបកប្រែរួច តែមិនទាន់បានទទួលការជូនដំណឹង។

[8] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ របស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ **E301/9/1/1/3**។

១២. ដូច្នេះ ក្រុមមេធាវីការពារក្ដីបារម្ភជាខ្លាំងពីថ្ងៃអនាគត។ ពីព្រោះថា ក្រុមមេធាវីការពារក្ដីពិតជានឹងបន្តស្នើសុំការបកប្រែជាភាសាបារាំង នូវសំណោរនានារបស់ភាគី និងទៅតាមតម្រូវការ សំណោររបស់អង្គជំនុំជម្រះនានា ក្នុងក្របខណ្ឌបណ្ដឹងសាទុក្ខ នៃសំណុំរឿង ០០២/០១ និងនីតិវិធីក្នុងសំណុំរឿង ០០២/០២។ ដោយមើលឃើញនូវភាពសាំញុំ និងសារសំខាន់នៃបញ្ហាចោទឡើងនៅក្នុងបណ្ដឹងសាទុក្ខ ក្រុមមេធាវីការពារក្ដីនឹងស្នើសុំឱ្យថិរវេលាសម្រាប់ឆ្លើយ និងឆ្លើយតបទៅនឹងព្រះរាជអាជ្ញា ចាប់ គិតពីពេលទទួលបានសេចក្ដីជូនដំណឹងជាភាសាបារាំង នៃសំណោររបស់ព្រះរាជអាជ្ញា។ [9]

## ២. តម្រូវការនៃការបកប្រែសំណោរពីភាសាបារាំងទៅភាសាខ្មែរ

១៣. ដោយសារតែជាក្រុមការងារតែមួយគត់ដែលត្រូវបំពេញការងារជាភាសាបារាំង បន្ថែមពីលើភាសាខ្មែរ ជាទូទៅ ក្រុមមេធាវីការពារក្ដីមិនបានជួបការលំបាកធំដុំឡើយ ក្នុងការស្នើសុំការបកប្រែពីភាសាបារាំងទៅជាភាសាខ្មែរ ក្នុងពេលបច្ចុប្បន្ន។

១៤. ក៏ប៉ុន្តែ កំណើនចំនួនសំណោរបន្ថែមជាច្រើននៃក្រុមមេធាវីការពារក្ដី ដែលមកពីបណ្ដឹងសាទុក្ខ (សំណើសុំ សារណា ចម្លើយ ចម្លើយតប) និងកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២/០២ នឹងនាំឱ្យមានភាពយឺតយ៉ាវជាខ្លាំង ប្រសិនបើសមត្ថភាពរបស់អង្គភាពបកប្រែមិនត្រូវបានពង្រឹងឱ្យបានឆាប់រហ័សទេនោះ។ ពីព្រោះថា ការដាក់ឯកសារជាភាសាខ្មែរ បន្ថែមពីលើភាសាបារាំង ឬពីលើភាសាអង់គ្លេស គឺជាចំណុចចាប់ផ្ដើមនៃថិរវេលាកំណត់។ [10]

១៥. ជាឧទាហរណ៍ ក្រុមមេធាវីការពារក្ដីទើបតែស្នើសុំតុលាការកំពូល ដើម្បីមានលទ្ធភាពដាក់សារណាបណ្ដឹងសាទុក្ខចំនួន ៣០០ ទំព័រ ជាភាសាបារាំង ដែលត្រូវការពេលវេលា ៨៥ ថ្ងៃ ដើម្បីបកប្រែជាភាសាខ្មែរ ទៅតាមល្បឿនធម្មតា។ [11]

---

[9] មាត្រា ៨.៥ នៃសេចក្ដីណែនាំអនុវត្ត។ សេចក្ដីសម្រេចលើសំណើរបស់សហមេធាវីការពារក្ដី ខៀវ សំផន សុំពន្យារពេលធ្វើការឆ្លើយតបទៅនឹងបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១២ **E163/5/1/2/1** កថាខណ្ឌទី៧។

[10] មាត្រា ៨.៥ នៃសេចក្ដីណែនាំអនុវត្ត។ សេចក្ដីសម្រេចលើសំណើបន្ទាន់របស់ អៀង សារី សុំដាក់បណ្ដឹងសាទុក្ខតែជាភាសាអង់គ្លេសសិន ហើយអត្ថបទជាភាសាខ្មែរនឹងដាក់តាមក្រោយ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៣ **E254/3/1/1.2** កថាខណ្ឌទី ៤។

[11] ការស្នើសុំជាបន្ទាន់របស់ លោក ខៀវ សំផន សុំពន្យារពេលកំណត់ និងបង្កើនចំនួនទំព័រនៅក្នុងសារណាបណ្ដឹង

## ៣. តម្រូវការនៃការបកប្រែសំណេរពីភាសាបារាំងទៅភាសាអង់គ្លេស

១៦. រហូតដល់ថ្ងៃនេះ ក្រុមមេធាវីការពារក្តី កម្រស្នើសុំការបកប្រែឯកសារជាភាសាអង់គ្លេសណាស់។ ក្រុមមេធាវីការពារក្តីបានស្នើសុំម្តងកាលពីនៅដំណាក់កាលអង្គជំនុំជម្រះសាលាដំបូង នៅពេលដែលខ្លួនដឹងថា គ្មានអ្នកណាបានស្នើសុំការបកប្រែជាភាសាអង់គ្លេស នូវសារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ខ្លួនដែលបានដាក់នៅ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ នោះឡើយ។[12] នៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣ ដោយសង្ឃឹមថា យ៉ាងហោចណាស់ ក៏ឯកសារបកប្រែនោះអាចទាញចំណាប់អារម្មណ៍ចៅក្រមនៃតុលាការកំពូល ក្នុងក្របខណ្ឌនៃបណ្តឹងសាទុក្ខប្រឆាំងសាលក្រម ក្រុមមេធាវីការពារក្តីក៏បានធ្វើការស្នើសុំដល់អង្គភាពបកប្រែ ហើយក៏បានក្រើនរំឭកទៅអង្គភាពនេះកាលពីប៉ុន្មានសប្តាហ៍មុននេះ។ រហូតដល់ថ្ងៃនេះ ឯកសារនេះនៅមិនទាន់បានបកប្រែនៅឡើយទេ។

១៧. ក្នុងពេលថ្មីៗនេះ ក្រុមមេធាវីការពារក្តី បានធ្វើការស្នើសុំការបកប្រែសំណេរជាភាសាអង់គ្លេស លើកទីពីរ ក្នុងក្របខណ្ឌនៃបណ្តឹងសាទុក្ខ។ ក្នុងទស្សនៈយល់ឃើញដែលថា ការបកប្រែជាភាសាអង់គ្លេសនូវសេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ[13] អាចនឹងទាញចំណាប់អារម្មណ៍ចៅក្រមនៃតុលាការកំពូល ក្រុមមេធាវីការពារក្តីក៏បានធ្វើការស្នើសុំនោះ បន្ទាប់ពីបានស្នើសុំការបកប្រែជាភាសាខ្មែរ។ ក៏ប៉ុន្តែ មួយថ្ងៃបន្ទាប់មក ប្រធានអង្គភាពបកប្រែបានទាក់ទងមកក្រុមមេធាវីការពារក្តីតាមទូរស័ព្ទ សុំឱ្យក្រុមមេធាវីដកការស្នើសុំបកប្រែជាភាសាអង់គ្លេសនោះវិញ។ ជាដំបូង ប្រធានអង្គភាពបកប្រែបានបន្ទោសក្រុមមេធាវីការពារក្តីថា ប្រមូលយកធនធានរបស់ខ្លួនផ្តាច់មុខអស់។ បន្ទាប់មក លោកបានអះអាងថា ការស្នើសុំនេះ មិនអនុលោមទៅតាមកាតព្វកិច្ចរបស់ភាគីទេ ដូច្នេះលោកមិនចាំបាច់បំពេញបំណងនេះឡើយ។ លោកបានបន្ថែមថា ភាគីសន្មត់ថាអាចបំពេញការងារជាបីភាសា ហើយរាល់ការបកប្រែសម្រាប់ក្រុមមេធាវីការពារក្តីពីភាសាអង់គ្លេស មកភាសាបារាំងទាំងអស់ដែលបានធ្វើឡើងរហូតដល់ពេលនេះ គឺត្រូវបានធ្វើឡើង *“ក្នុងករណីពិសេស”*។ ក្រុមមេធាវីការពារក្តី បានសុំឱ្យលោកយោងទៅ

---

សាទុក្ខ ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១៤ **F7** កថាខណ្ឌទី ១៩។

[12] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ **E295/6/4**។

[13] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី លោក ខៀវ សំផន ប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០១ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ **E313/2/1**។

អត្ថបទច្បាប់ជាធរមាន ហើយបដិសេធមិនដកសំណើសុំបកប្រែរបស់ខ្លួននេះឡើយ។

១៨. ពាក្យពេចន៍របស់ប្រធានអង្គភាពបកប្រែ មិនត្រឹមតែផ្ទុយទៅនឹងអ្វីដែលបានរំឭកជូនខាងលើនេះប៉ុណ្ណោះទេ (ក្នុងផ្នែក I) តែវាបង្ហាញថា អង្គភាពបកប្រែមានការងារច្រើនហួសប្រមាណ និងមិនអាចបំពេញតាមបំណងនៃការស្នើសុំរបស់ក្រុមមេធាវីការពារក្ដី ក្នុងការបកប្រែឯកសារជាភាសាអង់គ្លេសបានឡើយ។

១៩. តែថា លើកលែងតែតុលាការកំពូលប្រកាសថា ការបកប្រែសំណេរនានារបស់ក្រុមមេធាវីការពារក្ដីជាភាសាអង់គ្លេស ជាការគ្មានប្រយោជន៍ អំណើះតទៅ ក្រុមមេធាវីការពារក្ដីសូមបញ្ជាក់ថា ខ្លួននឹងស្នើសុំដល់អង្គភាពបកប្រែនេះ ឲ្យបកប្រែសារណាបណ្ដឹងសាទុក្ខ ចម្លើយទៅនឹងសារណារបស់សហព្រះរាជអាជ្ញា ព្រមទាំងចម្លើយតបនឹងចម្លើយរបស់សហព្រះរាជ-អាជ្ញាទៅនឹងសារណារបស់ក្រុមមេធាវីការពារក្ដី ជាភាសាខ្មែរ និងជាភាសាអង់គ្លេសថែមទៀតផង។

## 4. តម្រូវការនៃការបកប្រែការកែតម្រូវប្រតិចារឹកសវនាការ

២០. នៅពេលចាប់ផ្ដើមសំណុំរឿង ០០២/០១ ក្រុមមេធាវីការពារក្ដីដឹងថា មានភាពខុសគ្នាខ្លាំងរវាងប្រតិចារឹកសវនាការ ក្នុងសំណៅជាភាសាផ្សេងៗគ្នានោះ។ ក្រុមមេធាវីការពារក្ដី ក៏បានស្នើសុំទៅសាលាដំបូងឲ្យបង្គាប់ឲ្យពិនិត្យឡើងវិញ នូវប្រតិចារឹកក្នុងសំណៅជាភាសាបារាំងទាំងអស់ដោយផ្អែកលើប្រតិចារឹកជាភាសាខ្មែរ។[14] ដោយអនុវត្តតាមនីតិវិធីដែលសាលាដំបូងបានណែនាំ[15] ក្រុមមេធាវីការពារបានប្រើប្រាស់ពេលវេលាដ៏វែង ក្នុងការកំណត់ឲ្យបានច្បាស់នូវភាពខុសគ្នាមួយចំនួន រួចមកក៏ស្នើសុំឲ្យមានការកែតម្រូវ ដែលទាំងក្រុមមេធាវីការពារក្ដីខ្លួនឯង កំពុងតែសរសេរសារណាបញ្ចប់ការពិភាក្សាដេញដោល។ កាលនោះ ក្រុមមេធាវីការពារក្ដីសង្ឃឹមថា ភាគី និងសាលាដំបូង អាចទទួលបានអត្ថប្រយោជន៍ពីការកែតម្រូវទាំងនោះ

[14] សំណើរបស់មេធាវីការពារក្ដីលោក ខៀវ សំផន សុំឲ្យពិនិត្យមើលឡើងវិញនូវប្រតិចារឹកសវនាការជាភាសាបារាំង ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១២ **E195**។

[15] ចម្លើយរបស់អង្គជំនុំជម្រះទៅនឹងសំណើរបស់មេធាវីការពារក្ដីលោក ខៀវ សំផន (E195) និងនីតិវិធីទៅថ្ងៃមុខដែលនឹងអនុវត្តចំពោះការកែតម្រូវប្រតិចារឹក ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១២ **E195/1**។

សម្រាប់សរសេរសារណាបញ្ចប់ សម្រាប់ធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ តែក៏សម្រាប់ការពិភាក្សាសម្រេចរបស់សាលាដំបូងផងដែរ។

២១. ជាឧទាហរណ៍ ក្រុមមេធាវីការពារក្ដីបានមើលឃើញ និងសុំឲ្យធ្វើការកែតម្រូវសម្រង់ប្រតិចារឹក ចំនួន ៤៧៣ នៅឆ្នាំ ២០១៣ (ដែលក្នុងនោះសម្រង់ប្រតិចារឹកចំនួន ២៧១ ទាក់ទងនឹងសក្ខីកម្មរបស់លោក François PONCHAUD) ព្រមទាំងសម្រង់ប្រតិចារឹកមួយ នៅឆ្នាំ ២០១៤។ លុះដល់ថ្ងៃទី១៧ ខែ កក្កដា ឆ្នាំ ២០១៤ ឃើញមានការកែតម្រូវប្រតិចារឹកទាំងមូលនៃការផ្ដល់សក្ខីកម្មជាភាសាខ្មែររបស់លោក François PONCHAUD តាមការស្នើរបស់សាលាដំបូង។ មកដល់ថ្ងៃនេះ ក្នុងខែតុលា ឆ្នាំ ២០១៤ នេះ មានការកែតម្រូវសម្រង់ប្រតិចារឹកតែចំនួន ២០ ប៉ុណ្ណោះដែលត្រូវបានធ្វើហើយ ស្របតាមការស្នើសុំរបស់ក្រុមមេធាវីការពារក្ដី។

២២. ក៏ប៉ុន្តែ ការស្នើសុំនេះមិនត្រឹមតែមិនហួសពេល តាំងពីសាលាដំបូងបានចេញសាលក្រមមកប៉ុណ្ណោះទេ តែការស្នើសុំទាំងនោះនឹងបន្តកើនចំនួនឡើង។ ពីព្រោះថា នៅពេលចាប់ផ្ដើមផ្ទៀងកំណត់ជើងទំព័រនៅក្នុងសាលក្រម ក្រុមមេធាវីការពារក្ដីក៏ចាប់ផ្ដើមរកឃើញភាពខុសគ្នារវាងប្រតិចារឹកក្នុងសំណៅជាភាសាផ្សេងៗគ្នា ទាំងនោះជាអ្វីដែលសាលាដំបូងយកជាបង្អែកសម្រាប់ទាញសេចក្ដីសន្និដ្ឋាន។

២៣. ត្រង់ចំណុចនេះ វារឹតតែចាំបាច់ណាស់ទៅទៀត ដែលត្រូវពង្រឹងសមត្ថភាពអង្គភាពបកប្រែឲ្យបានឆាប់រហ័ស ដើម្បីបំពេញតាមតម្រូវការរបស់ក្រុមមេធាវីការពារក្ដី ឲ្យទាន់ពេលវេលា សម្រាប់បណ្ដឹងសាទុក្ខរបស់ខ្លួន។

## III. **អំណាចបង្គាប់របស់អង្គជំនុំជម្រះ**

២៤. វាជាការច្បាស់ណាស់ដែលថា ចៅក្រមមានអំណាចក្នុងការបង្គាប់ឲ្យផ្នែករដ្ឋបាលតុលាការពង្រឹងជាបន្ទាន់នូវសមត្ថភាពរបស់អង្គភាពបកប្រែភាសា។ ម្យ៉ាងទៀត សាលាដំបូងក៏ធ្លាប់បានប្រើប្រាស់អំណាចបែបនោះ កាលពីមុនដែរ *"ដើម្បីជម្រុញឲ្យអង្គភាពបកប្រែភាសាមានបុគ្គលិកគ្រប់គ្រាន់ សម្រាប់ផ្ដល់ជូននូវសេវាបកប្រែ ដែលស្នើសុំដោយអង្គជំនុំជម្រះ និងភាគីក្នុងសំណុំរឿងលេខ ០០២"* ។ [16]

[16] ទាក់ទងនឹងបញ្ហានៃការបកប្រែភាសានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២ និងដំណែងដែល

២៥. វាក៏ជាការច្បាស់ណាស់ដែរ ដែលថាក្រុមមេធាវីការពារក្ដី នឹងចំណាយពេល និងថាមពល យ៉ាងច្រើន ក្នុងការស្នើសុំអង្គភាពបកប្រែ នៅពេលក្រោយៗទៀត។ ការស្នើសុំបកប្រែរបស់ក្រុមមេធាវីការពារក្ដីមានភាពចាំបាច់ សម្រាប់ឲ្យក្រុមមេធាវីការពារក្ដីអាចបំពេញការងារ និងបំពេញកាតព្វកិច្ចរបស់ខ្លួន ចំពោះមុខកូនក្ដី។ សំណើសុំនីមួយៗសុទ្ធតែមានហេតុផល និងអនុលោមតាមច្បាប់អនុវត្ត។ វាក៏មិនមែនជាការផ្គាប់ចិត្តក្រុមមេធាវីការពារក្ដីនោះដែរ នៅពេលដែលអង្គភាពបកប្រែបំពេញតាមតម្រូវការណាមួយ របស់ក្រុមមេធាវីការពារក្ដីនោះ។ សូមរំឭកថា មុនអ្វីៗទាំងអស់ វាជាការអនុញ្ញាតដល់អង្គជំនុំជម្រះទាំងអស់ មាននៅក្នុងដៃនូវអំណះអំណាងទាំងអស់របស់ក្រុមមេធាវីការពារក្ដី និងភស្តុតាងនានាកំណត់ដោយភាគី ដើម្បីវិនិច្ឆ័យក្ដី។

២៦. វាជាការច្បាស់ណាស់ដែលថា សព្វថ្ងៃ អង្គភាពបកប្រែ គ្មានសមត្ថភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់អង្គជំនុំជម្រះ និងភាគីឡើយ ហើយស្ថានភាពនេះនឹងកាន់តែធ្ងន់ធ្ងរឡើង ប្រសិនជាមិនបានដោះស្រាយឲ្យបានឆាប់រហ័សទេនោះ។

២៧. ទីបញ្ចប់ ក្រុមមេធាវីការពារក្ដីសូមទទួចសុំជាពិសេស ចំពោះការដែលថា ខ្លួនជាអ្នកទីមួយដែលមានបំណងចង់ឲ្យមានការសម្រេចឲ្យបានឆាប់បំផុត លើបណ្ដឹងសាទុក្ខរបស់ខ្លួន។ ក្រុមមេធាវីការពារក្ដីដឹងថា ថិរវេលាកំណត់ខ្លះ មិនអាចបង្រួញបញ្ចូលគ្នាបានទេ (ការសរសេរ ការពិភាក្សាសម្រេច)។ តែថិរវេលាកំណត់សម្រាប់ការបកប្រែអាចកាត់បន្ថយបាន ប្រសិនបើអង្គភាពបកប្រែមានធនធានគ្រប់គ្រាន់នោះ។

## អាស្រ័យហេតុនេះ

ក្រុមមេធាវីការពារក្ដីរបស់ លោក ខៀវ សំផន ស្នើសុំអង្គជំនុំជម្រះតុលាការកំពូលមេត្តា ៖

- **បង្គាប់ឲ្យ**ផ្នែករដ្ឋបាលតុលាការពង្រឹងជាបន្ទាន់ នូវសមត្ថភាពរបស់អង្គភាពបកប្រែភាសា

នៅទំនេរនៅក្នុងអង្គភាពបកប្រែភាសាថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០១១ E38/1។

- **បង្គាប់ឲ្យ**អង្គភាពបកប្រែភាសាចាត់ចែងការងារទាំងស្រុង តាមសំណើរបស់ក្រុមមេធាវីការពារក្តី ទាំងសំណើពីមុន និងសំណើនៅថ្ងៃខាងមុខ ឲ្យបានឆាប់រហ័សបំផុតតាមតែអាចធ្វើទៅបាន។

**រក្សាសិទ្ធិកែប្រែគ្រប់យ៉ាង
និងដើម្បីយុត្តិធម៌**

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br>មេធាវី Anta GUISSÉ<br>មេធាវី Arthur VERCKEN | ភ្នំពេញ<br>ប៉ារីស<br>ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |